# ព្រះរាជក្រម

នស/រកម/០៨០៩/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការជំទាស់អ្វីឡើយ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃ
# អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃ
# ការរើសអើងប្រឆាំងនឹងនារីភេទ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារតាមជម្រើសនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលធ្វើនៅទីក្រុងញូយ៉ក នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារតាមជម្រើសនៃអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

នស/រកម.០៨០៩.០៣៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

ហត្ថលេខា

អ៊ឹង កន្ថាផាវី

លេខ: ៧៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ...៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ពិធីសារបោះជម្រើស
# នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

**(Optional Protocol of CEDAW)**

*អនុម័តដោយសេចក្តីសម្រេចចិត្តលេខ A/54/4 នៃមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៩ និងបើកចំហរសម្រាប់ការចុះហត្ថលេខានៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលជាទិវាសិទ្ធិមនុស្ស ចូលជាធរមាននៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០០ (តាមមាត្រា ១៦)*

រដ្ឋភាគីទាំងឡាយនៃពិធីសារនេះ,

*ដោយកត់សំគាល់ថា* ធម្មនុញ្ញអង្គការសហប្រជាជាតិ អះអាងឡើងវិញនូវជំនឿលើសិទ្ធិមនុស្ស ជាមូលដ្ឋាននៃសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់មនុស្ស និងសិទ្ធិស្មើគ្នារបស់បុរស និងស្ត្រី

*ដោយកត់សំគាល់ផងដែរថា* សេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្ស នៅក្នុងសេចក្តីសម្រេចចិត្ត លេខ 217A ( III ) ប្រកាសថា មនុស្សជាតិគ្រប់រូបកើតមកជាមួយនឹងសេរីភាព និងភាពស្មើគ្នាក្នុង សេចក្តីថ្លៃថ្នូរ និងសិទ្ធិនានា និងថាបុគ្គលគ្រប់រូបមានសិទ្ធិទទួលនូវសិទ្ធិនានា និងសេរីភាពទាំងអស់ ដែល មានចែងក្នុងសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្សខាងលើដោយគ្មានការរើសអើង រាប់បញ្ចូលទាំងការ រើសអើងភេទផងនោះ -

*ដោយចងចាំថា* កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្ស នៅក្នុងសេចក្តីសម្រេចលេខ ២២០០ A (XXI) ក្នុងឧបសម្ព័ន្ធ និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងទៀត ហាមឃាត់ការរើសអើងភេទ

*ដោយចងចាំផងដែរថា* អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី ភេទ " អនុសញ្ញា " ដែលក្នុងនោះរដ្ឋភាគីធានាថ្កោលទោសរាល់ទម្រង់ទាំងអស់នៃការរើសអើងប្រឆាំង នារីភេទ និងយល់ព្រមបន្តអនុវត្តគោលនយោបាយនៃការលុបបំបាត់នូវការរើសអើងប្រឆាំងនារីភេទ ដោយមធ្យោបាយសមស្របគ្រប់បែបយ៉ាង និងដោយគ្មានការបង្អែរបង្អង់

*ហើយអះអាងឡើងវិញ* នូវការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីធានាថា ស្ត្រីទទួលបាននូវសិទ្ធិ និងសេរីភាព ជាមូលដ្ឋានទាំងអស់ដោយពេញលេញ និងដោយស្មើភាព ហើយចាត់ការដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភសិទ្ធិ និងសេរីភាពទាំងឡាយ

*បានព្រមព្រៀងគ្នាដូចតទៅ* :

## មាត្រា ១

*រដ្ឋភាគីមួយនៃពិធីសារនេះ ( រដ្ឋភាគី )* ទទួលស្គាល់នូវសមត្ថកិច្ចរបស់គណៈកម្មាធិការ ស្តីពីការលុបបំបាត់ចោលនូវការរើសអើងប្រឆាំងនារីភេទ ( គណៈកម្មាធិការ ) ដើម្បីទទួល និងពិចារណាលើលិខិតបណ្តឹងនានាដែលត្រូវបានដាក់ជូនគណៈកម្មាធិការ ស្របតាមមាត្រា ២ ។

## មាត្រា ២

លិខិតបណ្តឹងទាំងនេះ អាចត្រូវបានដាក់ជូនដោយ ឬ ក្នុងនាមបុគ្គលម្នាក់ៗ ឬក្រុមនៃបុគ្គលដែលស្ថិតនៅក្រោម *យុត្តាធិការ* របស់រដ្ឋភាគី ដោយបានទាមទារថា ពួកគេរងគ្រោះដោយការរំលោភសិទ្ធិណាមួយ ដែលមានចែងនៅក្នុងអនុសញ្ញាដោយរដ្ឋភាគីនោះ ។ នៅកន្លែងដែលលិខិតបណ្តឹងត្រូវបានដាក់ជូនប្តឹងក្នុងនាមបុគ្គល ឬក្រុមនៃបុគ្គល ត្រូវមានការយល់ព្រមពីពួកគេទាំងនោះ ឬយ៉ាងហោចណាស់លុះត្រាតែអ្នកសរសេរលិខិតបណ្តឹង នោះអាចបញ្ជាក់ថាខ្លួនដើរតួប្តឹងជំនួសពួកគេ បើពុំមានការយល់ព្រមទេ ។

## មាត្រា ៣

លិខិតបណ្តឹងទាំងនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមិនត្រូវធ្វើជាលក្ខណៈអនាមិកឡើយ ។ គណៈកម្មាធិការនឹងមិនទទួលលិខិតបណ្តឹងឡើយ ប្រសិនបើលិខិតបណ្តឹងនោះពាក់ព័ន្ធនឹងរដ្ឋភាគីមួយនៃអនុសញ្ញា តែមិនមែនជាភាគីនៃពិធីសារនេះ ។

## មាត្រា ៤

១. គណៈកម្មាធិការនឹងមិនពិចារណាលើលិខិតបណ្តឹងឡើយ ប្រសិនបើដឹងប្រាកដថា ដំណោះស្រាយទាំងអស់ដែលមាននៅក្នុងប្រទេស មិនទាន់ត្រូវបានប្រើប្រាស់ឱ្យអស់លទ្ធភាព ឬការអនុវត្តដំណោះស្រាយទាំងនោះត្រូវបានអូសបន្លាយដោយមិនសមហេតុផល ឬមិនទំនងជាអាចនាំមកនូវភាពធូរស្រាលប្រកបដោយប្រសិទ្ធភាពបានទេ ។

២. គណៈកម្មាធិការនឹងអាចប្រកាសថា លិខិតបណ្តឹងមិនអាចទទួលយកបាន ប្រសិនបើ :

(ក) បញ្ហាដដែលនោះ ត្រូវបានពិនិត្យដោយគណៈកម្មាធិការរួចហើយ ឬក៏បាននិងកំពុងពិនិត្យ ឬកំពុងពិនិត្យ ក្រោមនីតិវិធីនៃការស៊ើបអង្កេតជាអន្តរជាតិ ឬដំណោះស្រាយអន្តរជាតិមួយផ្សេងទៀត

(ខ) លិខិតបណ្តឹងនោះ មិនស្របនឹងបទប្បញ្ញត្តិនានានៃអនុសញ្ញា

(គ) លិខិតបណ្តឹងនោះ មិនមានមូលដ្ឋានត្រឹមត្រូវជាក់ស្តែង ឬមិនមានភស្តុតាងគ្រប់គ្រាន់

(ឃ)គឺជាការរំលោភបំពានលើសិទ្ធិក្នុងការដាក់លិខិតបណ្តឹង

(ង) ហេតុការណ៍នានាដែលជាប្រធានបទនៃលិខិតបណ្តឹងនោះ បានកើតឡើងមុនពិធីសារនេះចូលជាធរមានសម្រាប់សាមីរដ្ឋភាគី លើកលែងតែហេតុការណ៍ទាំងនោះបានបន្តក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ ។

## មាត្រា ៥

១. នៅពេលណាមួយ ក្រោយពីទទួលបាននូវលិខិតបណ្តឹង និងមុនពេលឈានដល់ការសម្រេចលើអង្គហេតុ គណៈកម្មាធិការអាចផ្ញើបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ សម្រាប់ពិនិត្យពិចារណាជាបន្ទាន់លើសំណើដែលរដ្ឋភាគីនោះ ត្រូវចាត់វិធានការបណ្តោះអាសន្ន ដែលចាំបាច់ដើម្បីចៀសវាងការខូចខាតដែលមិនអាចប៉ះប៉ូវបានចំពោះជនរងគ្រោះ ឬជនរងគ្រោះទាំងឡាយដែលគេចោទថា បានត្រូវរំលោភ ។

២. នៅពេលដែលគណៈកម្មាធិការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ នេះមិនមែនមានន័យថាជាការសម្រេចលើភាពអាចទទួលយកបាន ឬលើអង្គហេតុនៃលិខិតបណ្តឹងនោះទេ ។

## មាត្រា ៦

១. ទោះបីគណៈកម្មាធិការពិនិត្យឃើញថា លិខិតបណ្តឹងមិនអាចយកជាការបានដោយគ្មានការយោងទៅលើសាមីរដ្ឋភាគីនោះ ប៉ុន្តែបើបុគ្គលម្នាក់ ឬបុគ្គលជាច្រើនយល់ព្រមបង្ហាញអត្តសញ្ញាណរបស់ពួកគេដល់រដ្ឋភាគីនោះ គណៈកម្មាធិការនឹងបញ្ជូនទៅសាមីរដ្ឋភាគីដោយសម្ងាត់នូវលិខិតបណ្តឹងដែលបានដាក់ជូនគណៈកម្មាធិការក្រោមពិធីសារនេះ ។

២. ក្នុងអំឡុងពេលប្រាំមួយខែ រដ្ឋភាគីដែលបានទទួលលិខិតបណ្តឹងពីគណៈកម្មាធិការ ត្រូវដាក់ជូនគណៈកម្មាធិការនូវការពន្យល់ ឬសេចក្តីថ្លែងការណ៍នានាជាលាយលក្ខណ៍អក្សរបំភ្លឺអំពីបញ្ហាខាងលើ និងដំណោះស្រាយ *(ប្រសិនបើមាន)* ដោយរដ្ឋភាគីនោះ ។

## មាត្រា ៧

១. គណៈកម្មាធិការនឹងពិចារណាលើលិខិតបណ្តឹងដែលខ្លួនបានទទួល ដូចមានចែងនៅក្នុងពិធីសារនេះ ទន្ទឹមនឹងព័ត៌មានទាំងអស់ដែលបានផ្តល់ជូនដោយ ឬក្នុងនាមបុគ្គលម្នាក់ ឬក្រុមនៃបុគ្គលក្តី និងដោយសាមីរដ្ឋភាគីក្តី ឱ្យតែព័ត៌មានទាំងនេះបានបញ្ជូនដល់ភាគីពាក់ព័ន្ធទាំងឡាយ ។

២. គណៈកម្មាធិការ ត្រូវរៀបចំការប្រជុំសម្ងាត់នៅពេលដែលខ្លួនកំពុងពិនិត្យលើលិខិតបណ្តឹងនានាក្រោមពិធីសារនេះ ។

៣. ក្រោយពីការពិនិត្យលិខិតបណ្តឹងនេះ គណៈកម្មាធិការត្រូវបញ្ជូនយោបល់នានារបស់ខ្លួនស្តីពីលិខិតបណ្តឹងទាំងនេះ ព្រមទាំងអនុសាសន៍នានា *(ប្រសិនបើមាន)* ទៅភាគីទាំងឡាយដែលពាក់ព័ន្ធ។

៤. រដ្ឋភាគី ត្រូវផ្តល់ការពិចារណា ក្នុងរយៈពេលមួយជាក់លាក់លើយោបល់នានារបស់គណៈកម្មាធិការ ព្រមទាំងអនុសាសន៍ផង និងត្រូវដាក់ជូនគណៈកម្មាធិការនូវចម្លើយជាលាយលក្ខណ៍អក្សរ រាប់បញ្ចូលទាំងព័ត៌មាន ស្តីពីចំណាត់ការណាមួយដែលបានចាត់ឡើងពាក់ព័ន្ធនឹងយោបល់ និងអនុសាសន៍របស់គណៈកម្មាធិការក្នុងរយៈពេលប្រាំមួយខែ ។

៥. គណៈកម្មាធិការ អាចស្នើសុំរដ្ឋភាគីឱ្យដាក់ជូននូវព័ត៌មានបន្ថែមអំពីវិធានការទាំងឡាយដែលរដ្ឋភាគីបានចាត់ការហើយ ឆ្លើយតបទៅនឹងយោបល់ ឬអនុសាសន៍នានារបស់ខ្លួន (ប្រសិនបើមាន) រួមទាំងអ្វីៗដែលគណៈកម្មាធិការយល់ថា ជាការសមស្របទៅក្នុងរបាយការណ៍លើកក្រោយរបស់រដ្ឋភាគីស្របតាមមាត្រា ១៨ នៃអនុសញ្ញា ។

## មាត្រា ៨

១. ប្រសិនបើគណៈកម្មាធិការទទួល ព័ត៌មានដែលគួរឱ្យជឿទុកចិត្តបានបង្ហាញពីការរំលោភសិទ្ធិធ្ងន់ធ្ងរ ឬមានលក្ខណៈជាប្រព័ន្ធដែលមានចែងនៅក្នុងអនុសញ្ញា គណៈកម្មាធិការនឹងស្នើសុំរដ្ឋភាគីនោះ ឱ្យជួយសហការក្នុងការត្រួតពិនិត្យព័ត៌មាន ហើយចុងបញ្ចប់ដាក់ជូននូវកត់សម្គាល់ទាំងឡាយទាក់ទិននឹងព័ត៌មាននោះ ។

២. ដោយពិចារណាលើមតិដែលបានមកពីការកត់សម្គាល់ ដែលអាចត្រូវបានដាក់ជូនដោយសាមីរដ្ឋភាគីក៏ដូចជាព័ត៌មានដែលគួរឱ្យជឿទុកចិត្តបានណាមួយផ្សេងទៀត ដែលខ្លួនមាននោះ *គណៈកម្មាធិការ* អាចជ្រើសតាំងសមាជិករបស់ខ្លួនម្នាក់ ឬច្រើននាក់ដើម្បីដឹកនាំធ្វើការស៊ើបអង្កេត និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ ។ ការស៊ើបអង្កេតអាចរាប់បញ្ចូលទស្សនកិច្ចទៅកាន់ដែនដីនៃរដ្ឋភាគីដែលត្រូវធានា និងយល់ព្រមដោយរដ្ឋភាគីនោះផង ។

៣. ក្រោយពីពិនិត្យលើលទ្ធផលនៃការស៊ើបអង្កេតបែបនោះ *គណៈកម្មាធិការ* នឹងផ្ញើលទ្ធផលទាំងនេះឱ្យទៅសាមីរដ្ឋភាគីរួមជាមួយនឹងយោបល់ និងអនុសាសន៍ផ្សេងៗផង ។

៤. សាមីរដ្ឋភាគី ក្នុងរយៈពេលប្រាំមួយខែនៃការទទួលលទ្ធផល យោបល់ និងអនុសាសន៍នានាដែលគណៈកម្មាធិការបានផ្ញើជូន ត្រូវដាក់ជូនគណៈកម្មាធិការនូវកំណត់សម្គាល់របស់ខ្លួន ។

៥. ការស៊ើបអង្កេតបែបនោះនឹងត្រូវធ្វើឡើងយ៉ាងសម្ងាត់ ហើយកិច្ចសហប្រតិបត្តិការរបស់រដ្ឋភាគីនឹងត្រូវបានផ្តល់នៅគ្រប់ដំណាក់កាលនៃដំណើរការប្តឹងទាំងនោះ ។

## មាត្រា ៩

១. *គណៈកម្មាធិការ* អាចស្នើសាមីរដ្ឋភាគីឱ្យបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន តាមមាត្រា ១៨ នៃអនុសញ្ញា នូវវិធានការណាមួយដែលខ្លួនបានចាត់ការរួចដោយលំអិត ឆ្លើយតបទៅនឹងការស៊ើបអង្កេត ដែលធ្វើឡើងតាមមាត្រា ៨ នៃពិធីសារនេះ ។

២. *គណៈកម្មាធិការ* អាចក្នុងករណីចាំបាច់ ស្នើឱ្យសាមីរដ្ឋភាគីផ្តល់ព័ត៌មានដល់ខ្លួន អំពីវិធានការទាំងឡាយដែលត្រូវបានចាត់ការរួច ឆ្លើយតបទៅនឹងការស៊ើបអង្កេតនោះក្រោយពីបញ្ចប់នៃរយៈពេលប្រាំមួយខែ ដែលបានចែងនៅក្នុងមាត្រា ៨.៤ ។

## មាត្រា ១០

១. រដ្ឋភាគីនីមួយៗអាច នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័នពិធីសារនេះ ឬចូលពិធីសារនេះ ប្រកាសថាខ្លួនមិនទទួលស្គាល់នូវសមត្ថកិច្ចរបស់គណៈកម្មាធិការ ដែលបានចែងនៅក្នុងមាត្រា ៨ និង ៩ ខាងលើ ។

២. រដ្ឋភាគីណាមួយដែលបានធ្វើការប្រកាស ស្របតាមវាក្យខ័ណ្ឌ ១ នៃមាត្រានេះ អាចដកសេចក្តីប្រកាសនេះចេញនៅពេលណាមួយក៏បាន ដោយការជូនដំណឹងដល់អគ្គលេខាធិការ ។

## មាត្រា ១១

រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាថា បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោម *យុត្តាធិការ* របស់រដ្ឋភាគី មិនត្រូវទទួលរងនូវអំពើអាក្រក់ ឬការបំភិតបំភ័យ ដែលជាផលវិបាកបណ្តាលមកពីការប្តឹងទៅគណៈកម្មាធិការឡើយ ដោយអនុលោមតាមពិធីសារនេះ ។

## មាត្រា ១២

គណៈកម្មាធិការនឹងបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន នូវសេចក្តីសង្ខេបមួយនៃសកម្មភាពរបស់ខ្លួនស្ថិតក្រោមពិធីសារនេះ ស្របតាមមាត្រា ២១ នៃអនុសញ្ញា។

## មាត្រា ១៣

រដ្ឋភាគីនីមួយៗ ទទួលរ៉ាប់រងផ្សព្វផ្សាយអនុសញ្ញា និងពិធីសារនេះឱ្យសាធារណៈជនបានដឹងយ៉ាងទូលំទូលាយ និងសម្រួលយ៉ាងណាឱ្យប្រព័ន្ធព័ត៌មានទទួលបានយោបល់ និងអនុសាសន៍នានារបស់គណៈកម្មាធិការ ជាពិសេសអំពីបញ្ហាទាំងឡាយដែលទាក់ទិននឹងរដ្ឋភាគីនោះ ។

## មាត្រា ១៤

គណៈកម្មាធិការត្រូវរៀបចំបង្កើតវិធាននីតិវិធីរបស់ខ្លួនដើម្បីប្រតិបត្តិតាម នៅពេលអនុវត្តមុខងារទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យដោយពិធីសារ ។

## មាត្រា ១៥

១. ពិធីសារនេះនឹងបើកចំហសំរាប់ការចុះហត្ថលេខាដោយរដ្ឋណាមួយ ដែលបានចុះហត្ថលេខាបានផ្តល់សច្ចាប័ន ឬចូលអនុសញ្ញា ។

២. ពិធីសារនេះ ត្រូវតែមានការផ្តល់សច្ចាប័នដោយរដ្ឋភាគីដែលបានផ្តល់សច្ចាប័ន ឬបានចូលអនុសញ្ញា ។ លិខិតុបករណ៍នានានៃការផ្តល់សច្ចាប័ននឹងត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

៣. ពិធីសារបច្ចុប្បន្ន នឹងបើកចំហសម្រាប់ការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនដោយរដ្ឋណាមួយដែលបានផ្តល់សច្ចាប័ន ឬបានចូលអនុសញ្ញា ។

៤. ការចូលអនុសញ្ញានឹងត្រូវចូលជាធរមាន ដោយការតម្កល់ទុកលិខិតុបករណ៍នៃការចូលជាមួយអគ្គលេខាធិការនៃអង្គការ សហប្រជាជាតិ ។

## មាត្រា ១៦

១. ពិធីសារបច្ចុប្បន្ននឹងចូលជាធរមានក្នុងរយៈពេលបីខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនូវលិខិតុបករណ៍ទី ១០ នៃការផ្តល់សច្ចាប័ន ឬការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុន ។

២. សម្រាប់រដ្ឋនីមួយៗ ដែលបានផ្តល់សច្ចាប័ន ឬបានផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនលើពិធីសារនេះ បន្ទាប់ពីពិធីសារបច្ចុប្បន្នបានចូលជាធរមានហើយ ពិធីសារបច្ចុប្បន្ននឹងចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយពីកាលបរិច្ឆេទនៃការដាក់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនរបស់ខ្លួនផ្ទាល់ ។

## មាត្រា ១៧

ពិធីសារនេះមិនអនុញ្ញាតឱ្យមានការដាក់លក្ខខ័ណ្ឌ ឬរក្សាទុកឡើយ ។

## មាត្រា ១៨

១. រដ្ឋភាគីណាមួយក៏ដោយ អាចស្នើសុំធ្វើវិសោធនកម្មចំពោះពិធីសារនេះហើយដាក់សំណើនេះជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិបាន ។ នៅពេលនោះ អគ្គលេខាធិការនឹងធ្វើសំណុំ

ឯកសារស្នើសុំធ្វើវិសោធនកម្ម នេះទៅរដ្ឋភាគីទាំងឡាយជាមួយនឹងសំណូមពរមួយសុំឱ្យពួកគេកត់សម្គាល់ខ្លួនឯង ថាតើពួកគេគាំទ្រឱ្យមានសន្និសីទមួយរបស់រដ្ឋភាគីទាំងឡាយក្នុងគោលបំណងពិចារណា និងបោះឆ្នោតលើសំណើនោះដែរឬអត់ ។ ក្នុងករណី ១/៣ យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានសន្និសីទបែបនោះ *អគ្គលេខាធិការ* នឹងកោះអញ្ជើញរដ្ឋភាគីសម្រាប់សន្និសីទនោះ ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ វិសោធនកម្មណាមួយ ដែលត្រូវបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងសន្និសីទនោះនឹងត្រូវបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីសម្រេច ។

២. វិសោធនកម្មនានានឹងចូលជាធរមាននៅពេលដែលវិសោធនកម្មទាំងនោះ ត្រូវបានសម្រេចដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ និងទទួលយកដោយមតិភាគច្រើន ២/៣ នៃរដ្ឋភាគីចំពោះពិធីសារនេះ អនុលោមទៅតាមដំណើរការនានានៃរដ្ឋធម្មនុញ្ញរៀងៗខ្លួនរបស់រដ្ឋភាគីទាំងឡាយនោះ ។

៣. នៅពេលដែលវិសោធនកម្មនានាចូលជាធរមាន វិសោធនកម្មទាំងនោះនឹងចងភ្ជាប់ជាមួយកាតព្វកិច្ចរបស់រដ្ឋភាគីទាំងឡាយដែលបានទទួលយកវិសោធនកម្មទាំងនោះ រដ្ឋភាគីផ្សេងទៀតនៅតែជាប់កាតព្វកិច្ចចំពោះបញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មពីមុនណាមួយដែលរដ្ឋភាគីទាំងនោះ បានទទួលយករួចហើយ ។

## មាត្រា ១៩

១. រដ្ឋភាគីនីមួយៗ អាចប្រកាសមិនយល់ព្រមចំពោះពិធីសារនេះនៅពេលណាមួយក៏បាន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ ការប្រកាសមិនយល់ព្រមនឹងចូលជាធរមានក្នុងរយៈពេល *ប្រាំមួយខែ* បន្ទាប់ពីថ្ងៃដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនោះពីរដ្ឋភាគី ។

២. ការប្រកាសមិនយល់ព្រម ត្រូវតែមិនមានការលំអៀងទៅរកការអនុវត្តដែលត្រូវបន្តនៃបញ្ញត្តិនានានៃពិធីសារនេះ ចំពោះលិខិតបណ្តឹងណាមួយដែលត្រូវបានដាក់ជូនមកគណៈកម្មាធិការ ក្រោមមាត្រា ២ ឬការស៊ើបអង្កេតណាមួយដែលត្រូវបានផ្តួចផ្តើមគំនិតក្រោមមាត្រា ៨ មុនថ្ងៃចូលជាធរមាននៃការប្រកាសមិនយល់ព្រមនោះ ។

## មាត្រា ២០

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់អំពី :

(ក) ការចុះហត្ថលេខានានា ការផ្តល់សច្ចាប័ននានា និងការផ្តល់សច្ចាប័នដោយពុំបានចុះហត្ថលេខាជាមុនទាំងឡាយ ក្រោមពិធីសារនេះ

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ និងនៃការធ្វើវិសោធនកម្មណាមួយ នៅក្រោមមាត្រា ១៨

(គ) ការប្រកាសមិនយល់ព្រមណាមួយ ក្រោមមាត្រា ១៩ ។

## មាត្រា ២១

១. ពិធីសារនេះ ដែលឯកសារដើមជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្បាញ៉ុល មានតម្លៃស្មើគ្នានោះ ត្រូវបានតម្កល់ទុកនៅក្នុងបណ្ណសាររបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិនឹងធ្វើច្បាប់នៃពិធីសារនេះ ដែលមានការបញ្ជាក់ថាត្រឹមត្រូវជូនរដ្ឋទាំងអស់ យោងទៅតាមមាត្រា ២៥ នៃអនុសញ្ញា ។